# ការចុះឈ្មោះក្នុងគម្រោងធានារ៉ាប់រង សុខភាពដែលមានគុណភាព
# ការណែនាំអំពីមួយជំហានម្តង

COVERED CALIFORNIA

**បើកការចុះឈ្មោះ នៅក្នុងខែវិច្ឆិកា ថ្ងៃទី1ខែមករាឆ្នាំ 2015 31, 2016.**

NOV 1 2015 – JAN 31 2016

**សម្រាប់ការធានារ៉ាប់រង ដែលចាប់ផ្តើមនៅថ្ងៃទី 1 ខែមករា ឆ្នាំ 2016 សូមចុះឈ្មោះនៅត្រឹម ថ្ងៃទី 15 ខែធ្នូ ឆ្នាំ 2015 ។**

Covered California™ គឺជាកម្មវិធីបង្កើតឡើងដោយរដ្ឋកាលីហ្វ័រញ៉ា ដែលអាចឱ្យអ្នកប្រៀបធៀប និងទិញគម្រោងធានារ៉ាប់រងសុខភាពឯកជន និងទទួលបានជំនួយហិរញ្ញវត្ថុដើម្បីបង់ថ្លៃធានារ៉ាប់រងសុខភាព បើអ្នកមានគុណសម្បត្តិ ។
ការណែនាំនេះនឹងជួយអ្នកយល់ដឹងកាន់តែច្បាស់អំពីជម្រើសរបស់អ្នក និងចុះឈ្មោះក្នុងគម្រោងសុខភាពដែលស័ក្តិសមនឹងតម្រូវការរបស់អ្នកបំផុត ។

## ជំហានទី 1: អ្នកអាចទទួលបានជំនួយក្នុងការបង់ថ្លៃធានារ៉ាប់រងសុខភាពបើអ្នកមានគុណសម្បត្តិ

ការមានធានារ៉ាប់រងសុខភាពធានាជូនអ្នកនូវភាពស្ងប់សុខផ្លូវចិត្ត ប្រសិនបើមានអ្វីដែលមិនរំពឹងទុកកើតឡើង ប៉ុន្តែយើងភាគច្រើនព្រួយបារម្ភអំពីការចំណាយ ។ ជំនួយហិរញ្ញវត្ថុក្នុងទម្រង់ជាឥណទានពន្ធមានជូនអ្នកដែលមានគុណសម្បត្តិផ្អែកលើទំហំ និងប្រាក់ចំណូលក្នុងគ្រួសារ - ប្រាក់ចំណូលរបស់អ្នកកាន់តែទាបអ្នកអាចទទួលបាននូវជំនួយហិរញ្ញវត្ថុកាន់តែច្រើនពី Covered California ។
បើអ្នកមិនមានគុណសម្បតទទួលបានជំនួយហិរញ្ញវត្ថុទេ អ្នកក៏អាចចុះឈ្មោះក្នុងគម្រោងធានារ៉ាប់រងសុខភាពតាមរយៈ Covered California ។

សូមមើលតារាងខាងក្រោមឬចូលទៅ Shop and Compare Tool នៅ CoveredCA.com ដើម្បីស្វែងយល់ថាតើគម្រោងរបស់អ្នកអាចចំណាយប៉ុន្មាន និងដើម្បីសិក្សាថាតើអ្នកមានគុណសម្បត្តិទទួលបានសម្រាប់ជំនួយហិរញ្ញវត្ថុ ឬ Medi-Cal ឬយ៉ាងនា ។

(សម្គាល់: "Shop and Compare Tool" មានជាភាសា អង់គ្លេស)

## ពិនិត្យមើលថាតើលោកអ្នកអាចមានសិទ្ធិទទួលបានជំនួយហិរញ្ញវត្ថុឬយ៉ាងណា:

| ចំនួនមនុស្សក្នុងគ្រួសាររបស់លោកអ្នក | ប្រសិនបើប្រាក់ចំណូលគ្រួសាររបស់លោកអ្នកនៅឆ្នាំ 2016 មានចំនួនតិចជាង... | ប្រសិនបើប្រាក់ចំណូលគ្រួសាររបស់អ្នកនៅឆ្នាំ 2016 ស្ថិតក្នុងចន្លោះ... |
|---|---|---|
| 1 | $16,243 | $16,243 – $47,080 |
| 2 | $21,984 | $21,984 – $63,720 |
| 3 | $27,725 | $27,725 – $80,360 |
| 4 | $33,466 | $33,466 – $97,000 |
| 5 | $39,206 | $39,206 – $113,640 |
| | លោកអ្នកអាចមានសិទ្ធិទទួលបាន Medi-Cal | លោកអ្នកអាចមានសិទ្ធិទទួលបានជំនួយហិរញ្ញវត្ថុ ដើម្បីទិញធានារ៉ាប់រងតាមរយៈ Covered California |



**បើអ្នកមានគុណសម្បត្តិទទួលបាន Medi-Cal:**

Medi-Cal គឺជាកម្មវិធីធានារ៉ាប់រងសុខភាព សាធារណៈដែល បម្រើពលរដ្ឋនៃរដ្ឋកាលីហ្វ័រញ៉ាដែលមានប្រាក់ចំណូលទាប ។

ប្រសិនបើអ្នកមានគុណសម្បត្តិសូមចូលទៅ CoveredCA.com ឬការិយាល័យសេវាកម្មសង្គមកិច្ចនៅក្នុងតំបន់របស់អ្នក ដើម្បីដាក់ពាក្យសុំ ។ អ្នកក៏អាចធ្វើការជាមួយអ្នកប្រឹក្សាការចុះឈ្មោះ ឬភ្នាក់ងារ ដែលមានទទួលស្គាល់ដោយ Covered California ដើម្បីទទួលបានជំនួយចុះឈ្មោះក្នុង Medi-Cal ។

## ជំហានទី 2: ស្វែងរកជម្រើសធានារ៉ាប់រងរបស់អ្នក ។

Covered California ផ្តល់ជូននូវគម្រោងសុខភាពជាច្រើន ដូច្នេះអ្នកអាចជ្រើសរើសគម្រោងមួយដែលបំពេញនូវតម្រូវការសុខភាព និងថវិការបស់អ្នកបានល្អបំផុត ។

## មុននឹងអ្នកជ្រើសរើសគម្រោងសុខភាពរបស់អ្នក សូមពិចារណាកត្តាទាំងនេះ:

**តើការធានារ៉ាប់រងកម្រិតណាដែលអ្នក និងគ្រួសារអ្នកត្រូវការ?** Covered California ផ្តល់ជូននូវគម្រោងសុខភាពជាច្រើនសម្រាប់ជ្រើសរើស ផ្អែកលើស្ថានភាពសុខភាព និងហិរញ្ញវត្ថុទាំងមូលរបស់អ្នក ។ នេះគឺជាអ្វីដែលអ្នកគួរពិចារណានៅពេលអ្នកជ្រើសរើសគម្រោងមួយ:

- **កម្រិតនៃការធានារ៉ាប់រង:**
  - **ជ្រើសរើស Platinum ឬ Gold...** ប្រសិនបើអ្នកនឹងត្រូវការការថែទាំច្រើន ។ គម្រោងទាំងនេះមានថ្លៃធានារ៉ាប់រងប្រចាំខែខ្ពស់ ដូច្នេះ ពេលអ្នកត្រូវការសេវាវេជ្ជសាស្រ្ត អ្នកអាចបង់ប្រាក់ កាន់តែតិច ។
    - **ជ្រើសរើស Silver ឬ Bronze...** ប្រសិនបើអ្នកមានសុខភាពល្អ និងមិនត្រូវការការថែទាំច្រើននោះទេ ។ ចំពោះគម្រោងទាំងនេះអ្នកអាចបង់ថ្លៃធានារ៉ាប់រងប្រចាំខែតិច ប៉ុន្តែ ត្រូវបង់ប្រាក់ច្រើនពេលអ្នកត្រូវការសេវាវេជ្ជសាស្រ្ត ។ សម្រាប់អ្នកទាំងឡាយដែលមានគុណសម្បត្តិគម្រោង Enhanced Silver ក៏អាចផ្តល់ជូននូវចំណាយចេញពីហោប៉ៅកាន់តែទាបផងដែរ ។
    - **គម្រោងធានារ៉ាប់រងអប្បបរមា** ក៏មានជូនអ្នកមានអាយុតិចជាង 30 ឆ្នាំ ឬអ្នកដែលអាចបញ្ជាក់ថាពួកគេកំពុងជួបការលំបាក ។ គម្រោងទាំងនេះមានថ្លៃទិញធានារ៉ាប់រងប្រចាំខែទាប និងការពារពីករណីសេណារីយ៉ូអាក្រក់ ។ អ្នកមិនអាចប្រើជំនួយហិរញ្ញវត្ថុដើម្បីជួយបង់គម្រោងធានារ៉ាប់រងអប្បបរមាទេ ។
- **តម្លៃរំពឹងទុក :**
  - ពេលពិចារណាពីគម្រោងមួយ ត្រូវប្រាកដច្បាប់ថាអ្នកយល់ដឹងយ៉ាងពេញលេញអំពីថ្លៃទិញធានារ៉ាប់រង តម្លៃត្រូវបង់ប្រចាំឆ្នាំមុនពេលធានារ៉ាប់រងបង់ឱ្យតម្លៃរួមចំណែកពេលទៅពេទ្យម្តងៗ និងកម្រិតចំណាយចេញពីហោប៉ៅ ដែលអ្នកនឹងទទួលខុសត្រូវ តើសេវាកម្មអ្វីខ្លះ ដែលបានធានារ៉ាប់រង និងថាតើគ្រូពេទ្យបច្ចុប្បន្នរបស់អ្នកទទួលយកនូវធានារ៉ាប់រងដែរឬទេ ។

## ស្តង់ដារផលប្រយោជន៍នៃការធានារ៉ាប់រងតាមកម្រិត

| ផលប្រយោជន៍សំខាន់ៗ | **Bronze** ធានារ៉ាប់រង **60%** នៃចំណាយប្រចាំឆ្នាំ | **Silver** ធានារ៉ាប់រង **70%** នៃចំណាយប្រចាំឆ្នាំ | **Gold** ធានារ៉ាប់រង **80%** នៃចំណាយប្រចាំឆ្នាំ | **Platinum** ធានារ៉ាប់រង **90%** នៃចំណាយប្រចាំឆ្នាំ |
|---|---|---|---|---|
| តម្លៃត្រូវបង់ ប្រចាំឆ្នាំមុនពេលធានារ៉ាប់រងបង់ឱ្យ | $6,000 | $2,250** | គ្មានតម្លៃត្រូវបង់ប្រចាំឆ្នាំទេ | គ្មានតម្លៃត្រូវបង់ប្រចាំឆ្នាំទេ |
| ការថែទាំការពារបង្ការប្រចាំឆ្នាំ | មិនមានចំណាយ | មិនមានចំណាយ | មិនមានចំណាយ | មិនមានចំណាយ |
| តម្លៃរួមចំណែកពេលទៅជួបពិនិត្យថែទាំសុខភាពបឋម | $70* | $45 | $35 | $20 |
| តម្លៃរួមចំណែក ពេលទៅពេទ្យម្តងៗ សម្រាប់ការថែទាំបន្ទាន់ | $120* | $90 | $60 | $40 |
| តម្លៃរួមចំណែកពេលទៅពេទ្យម្តងៗ សម្រាប់បន្ទប់សង្គ្រោះបន្ទាន់ | Full cost up to deductible | $250 | $250 | $150 |
| តម្លៃរួមចំណែក ពេលទៅពេទ្យម្តងៗ សម្រាប់ថ្នាំ Generic | Full cost up to $500 deductible | $15 | $15 | $5 |
| ចំណាយចេញពីហោប៉ៅអតិបរមាប្រចាំឆ្នាំសម្រាប់មនុស្សម្នាក់ | $6,500 | $6,250 | $6,200 | $4,000 |
| ចំណាយចេញពីហោប៉ៅអតិបរមាប្រចាំឆ្នាំសម្រាប់គ្រួសារ** | $13,000 | $12,500 | $12,400 | $8,000 |

*តារាងមិនបានបញ្ចូលគ្រប់អត្រាសហធានារ៉ាប់រង និងតម្លៃរួមចំណែក ពេលទៅពេទ្យម្តងទាំងអស់ទេ ។ សម្រាប់ព័ត៌មានពេញលេញសូម ចូលទៅ www.CoveredCA.com*

* *សម្រាប់គម្រោង Bronze តម្លៃត្រូវបង់ប្រចាំឆ្នាំ មុនពេលធានារ៉ាប់រងបង់ឱ្យត្រូវបានលើកលែងសម្រាប់ជំនួបថែទាំបឋមចំនួនបីដងដំបូង ។ ជំនួបបន្ថែមត្រូវគិតថ្លៃគ្រប់ចំនួនដល់បង់គ្រប់តម្លៃត្រូវបង់ប្រចាំឆ្នាំ មុនពេលធានារ៉ាប់រងបង់ឱ្យ ។*

** *Silver គឺជាកម្រិតតែមួយគត់ ដែលតម្លៃត្រូវបង់ប្រចាំឆ្នាំ មុនពេលធានារ៉ាប់រងបង់ឱ្យរបស់អ្នក និងចំណាយផ្សេងទៀតអាចមានចំនួនទាប ផ្អែកលើប្រាក់ចំណូលក្នុងគ្រួសាររបស់អ្នក ។*

សម្រាប់ការពន្យល់ពេញលេញអំពីកម្រិតផ្សេងៗនៃការធានារ៉ាប់រងនិងដើម្បីស្វែងរកជម្រើសរបស់អ្នក សូមចូលទៅ **www.CoveredCA.com** ។

# ការចុះឈ្មោះក្នុងគម្រោងធានារ៉ាប់រងសុខភាពដែលមានគុណភាព

## ការណែនាំអំពីមួយជំហានម្តង

**តើមានបណ្តាញអ្នកផ្តល់សេវាអ្វីខ្លះក្នុងតំបន់របស់អ្នក?** Covered California អាចឱ្យអ្នកជ្រើសរើស និងទិញគម្រោងធានារ៉ាប់រងឯកជនពីអ្នកផ្តល់សេវាថែទាំសុខភាពដែលអាចជឿទុកចិត្តបាន ។ ខណៈដែលក្រុមហ៊ុនធានារ៉ាប់រងទាំងអស់ផ្តល់ជូនកម្រិតនៃការធានារ៉ាប់រងដូចគ្នា ពួកគេផ្តល់ជូនប្រភេទគម្រោង និង បណ្តាញអ្នកផ្តល់សេវាថែទាំផ្សេងពីគ្នា (គ្រូពេទ្យ និងមន្ទីរពេទ្យក្នុងតំបន់របស់អ្នកដែលទទួលយកនូវការធានារ៉ាប់រងរបស់អ្នក) ។ ប្រសិនបើអ្នកចង់បន្តជួបគ្រូពេទ្យបច្ចុប្បន្នរបស់អ្នក សូមស្វែងរកថាតើគម្រោងមួយណាដែលបញ្ចូលគ្រូពេទ្យនោះជាសមាជិកក្នុងបណ្តាញរបស់ពួកគេ ។

**តើប្រភេទគម្រោងអ្វីដែលល្អបំផុតសម្រាប់គ្រួសាររបស់អ្នក?** ក្រុមហ៊ុនធានារ៉ាប់រងភាគច្រើនផ្តល់ជូនគម្រោងធានារ៉ាប់រងបីប្រភេទ អង្គការថែទាំសុខភាព (HMOs) អង្គការអ្នកផ្តល់សេវាដែលពេញចិត្ត (PPOs) និងអង្គការអ្នកផ្តល់សេវាផ្តាច់មុខ (EPOs) ។ ប្រភេទគម្រោងទាំងនេះកំណត់ពីគ្រូពេទ្យ និងមន្ទីរពេទ្យដែលអ្នកអាចទៅជួបបាន និងពីរបៀបដែលអ្នកប្រើប្រាស់សេវាសុខភាពមួយចំនួន ។

- **HMOs** ធានារ៉ាប់រងតែការទៅជួបគ្រូពេទ្យ និងមន្ទីរពេទ្យក្នុងបណ្តាញរបស់គម្រោងប៉ុណ្ណោះ ។ HMOs ជារឿយៗតម្រូវឱ្យសមាជិកទទួលបានសំបុត្របញ្ជូនពី វេជ្ជបណ្ឌិតថែទាំសុខភាពបឋម ដើម្បីទៅជួបអ្នកឯកទេស ។
- **PPOs** បង់ថ្លៃទៅជួបគ្រូពេទ្យក្នុង និងក្រៅបណ្តាញរបស់គម្រោង ប៉ុន្តែសមាជិកបង់ចំណាយកាន់តែខ្ពស់ សម្រាប់ការថែទាំសុខភាពនៅក្រៅបណ្តាញ ។
- ជាទូទៅ **EPOs** មិនធានារ៉ាប់រងការថែទាំក្រៅបណ្តាញរបស់ គម្រោងទេ ប៉ុន្តែសមាជិកអាចមិនត្រូវសំបុត្របញ្ជូន ដើម្បីទៅជួបអ្នកឯកទេសក្នុងបណ្តាញ ។

មានសារៈសំខាន់ត្រូវចងចាំថា PPOs HMOs និង EPOs មិនសុទ្ធតែដូចគ្នាទេ ។ ត្រូវប្រាកដថាប្បាប់ថាអ្នកបានទទួលរាល់ព័ត៌មានលម្អិតអំពីគម្រោង — ដូចជាថាតើគ្រូពេទ្យនិងមន្ទីរពេទ្យអ្វីត្រូវបានធានារ៉ាប់រង និងថាតើនឹងត្រូវចំណាយប៉ុន្មានដើម្បីទៅជួប គ្រូពេទ្យក្រៅបណ្តាញ — មុនពេលអ្នកធ្វើការជ្រើសរើស ។

### ជំហានទី 3: ប្រមូលព័ត៌មានដែលអ្នកត្រូវការ ។

ពេលអ្នកជ្រើសរើសគម្រោងដែលស័ក្តិសមចំពោះអ្នក វាជាពេលវេលាត្រូវចាប់ផ្តើមដំណើរការចុះឈ្មោះ ។ ត្រូវប្រាកដច្បាស់ថាអ្នកក្រដាសត្រឹមត្រូវ និងព័ត៌មានរួចរាល់ នៅពេលអ្នកដាក់ពាក្យសុំ ។

### សម្រាប់សមាជិកគ្រួសារម្នាក់ៗដែលនឹងត្រូវបានធានារ៉ាប់រងដោយគម្រោងសុខភាព (រាប់បញ្ចូលទាំងរូបអ្នក) អ្នកគួរតែមាន :




ព័ត៌មានស្តីពីប្រាក់ចំណូល* – លិខិតប្រកាសពន្ធ ឆ្នាំ 2015 សន្លឹកបើកប្រាក់ថ្មីៗ និង/ឬបែបបទ W-2



អត្តសញ្ញាណ - ប័ណ្ណបើកបររដ្ឋកាលីហ្វ័រញ៉ា អត្តសញ្ញាប័ណ្ណ រដ្ឋកាលីហ្វ័រញ៉ា លិខិតឆ្លងដែនអាមេរិក ឬទម្រង់ផ្សេងទៀតនៃ ប័ណ្ណសម្គាល់អត្តសញ្ញាណ ។



ភស្តុតាងនៃសញ្ជាតិ ឬវត្តមានស្របច្បាប់ - លិខិតឆ្លងដែន អាមេរិក ប័ណ្ណស្នាក់នៅស្របច្បាប់ ឬឯកសារសញ្ជាតូបនីយកម្ម

### ម្យ៉ាងទៀត ចំពោះរាល់សមាជិកក្នុងគ្រួសារទាំងអស់ដែលដាក់ពាក្យសុំ អ្នកគួរដឹង:



លេខសន្តិសុខសង្គម** (ប្រសិនបើជាពលរដ្ឋអាមេរិក)



ថ្ងៃខែឆ្នាំកំណើត



លេខកូដប្រៃសណីយ៍ផ្ទះ

**ការទទួលបានការធានារ៉ាប់រងមិនត្រឹមតែជាជម្រើសល្អបំផុតសម្រាប់សុខភាពអ្នកទេ — គឺវាជាច្បាប់ ។**



ត្រឹមខែមករា ឆ្នាំ 2014 មនុស្សភាគច្រើនត្រូវបានតម្រូវឱ្យមានធានារ៉ាប់រងសុខភាព ឬបង់ពិន័យពន្ធ ។

ក្នុងឆ្នាំ 2016 ការពិន័យនឹងមានចំនួន 2.5 ភាគរយនៃប្រាក់ ចំណូលគ្រួសារប្រចាំឆ្នាំរបស់អ្នក ឬ $695 សម្រាប់មនុស្សពេញវ័យម្នាក់ (និង $347.50 សម្រាប់កុមារម្នាក់ក្រោមអាយុ 18 ឆ្នាំ) គឺចំនួនមួយណាក៏ដោយដែលជាចំនួនខ្ពស់ជាងគេ ។

* ភស្តុតាងចំណូលបច្ចុប្បន្នរបស់សមាជិកគ្រួសារទាំងអស់ដែលដាក់ពាក្យសុំ ។ (ប្រាក់ចំណូលរបស់អ្នកក្នុងបន្ទុកគួរបញ្ចូល តែក្នុងករណីកម្រិតប្រាក់ចំណូលរបស់ពួកគេតម្រូវឱ្យពួកគេដាក់លិខិតប្រកាស ពន្ធប៉ុណ្ណោះ ។) គ្រួសារត្រូវបានកំណត់និយមន័យថាជាមនុស្សដែលប្រកាសពន្ធជាមេគ្រួសារ និងរាល់អ្នកក្នុងបន្ទុកទាំងអស់ដែលបានអះអាងក្នុងលិខិតប្រកាសពន្ធរបស់បុគ្គលនោះ ។ ប្រសិនបើអ្នកមិនប្រកាសពន្ធទេ អ្នកនៅតែអាចមានគុណ សម្បត្តិទទួលបានការធានារ៉ាប់រងដោយឥតគិតថ្លៃ ឬតម្លៃទាបតាមរយៈ Medi-Cal ។

** គ្រួសារដែលរាប់បញ្ចូលទាំងជនអន្តោប្រវេសន៍មិនស្របច្បាប់អាចដាក់ពាក្យសុំបាន ។ អ្នកអាចដាក់ពាក្យសុំឱ្យកូនរបស់អ្នក បើទោះបីអ្នកមិនមានសិទ្ធិទទួលបានការធានារ៉ាប់រងក៏ដោយ ។

## ជំហានទី 4: បង្កើតគណនី និងចុះឈ្មោះ ។

អ្នកអាចចុះឈ្មោះក្នុងគម្រោងរបស់អ្នកតាមអ៊ីនធើណេតនៅ **www.CoveredCA.com** ។ អ្វីដែលអ្នកត្រូវធ្វើ គឺបង្កើតគណនីអ្នកប្រើប្រាស់មួយ និង អនុវត្តតាមដំណើរការចុះឈ្មោះ ដោយប្រើប្រាស់ព័ត៌មានដែលអ្នកបានប្រមូលក្នុងជំហានទី 3 ។

ប្រសិនបើអ្នកត្រូវការជំនួយក្នុងការចុះឈ្មោះ Covered California ផ្តល់ជំនួយឥតគិតថ្លៃ និងរក្សាការសម្ងាត់នៅក្បែរអ្នក។

ដើម្បីស្វែងរកជំនួយក្នុងតំបន់ សូមចូលទៅ **www.CoveredCA.com/enrollment-assistance** និងវាយបញ្ចូលលេខកូដប្រៃសណីយ៍របស់អ្នក ។ អ្នកអាចទូរស័ព្ទមកពួកយើងតាមលេខ (800) 300-1506 ។

## ជំហានទី 5: រក្សាទុកព័ត៌មានសំខាន់ ។

ក្នុងករណីអ្នកមានសំណួរអំពីការធានារ៉ាប់រងរបស់អ្នកក្នុងពេលអនាគត ជាការសំខាន់ ត្រូវរក្សាទុកនូវកំណត់ត្រាឈ្មោះ និងលេខមួយចំនួនពីក្នុងពាក្យសុំ និងគម្រោងធានារ៉ាប់រងរបស់អ្នក។ ត្រូវប្រាកដច្បាស់ថា អ្នកកត់ទុកព័ត៌មានសំខាន់នេះ:

លេខសម្គាល់ពាក្យសុំរបស់អ្នក

លេខករណីរបស់អ្នក

ឈ្មោះក្រុមហ៊ុនធានារ៉ាប់រងសុខភាពរបស់អ្នក

ព័ត៌មានអំពីគម្រោងធានារ៉ាប់រងរបស់អ្នក (លេខគម្រោង លេខក្រុម ជាដើម ។)

ឈ្មោះ និងព័ត៌មានទាក់ទងរបស់អ្នកប្រឹក្សាការចុះឈ្មោះដែលមានការទទួលស្គាល់ (CEC) ទីភ្នាក់ងារធានារ៉ាប់រងដែលមានការទទួលស្គាល់ (CEC) ឬអ្នកចុះឈ្មោះតាមគម្រោង (PEB) ដែលបានជួយអ្នកចុះឈ្មោះ

## ជំហានទី 6: បង់ថ្លៃទិញធានារ៉ាប់រងរបស់អ្នក ។

រៀងរាល់ខែ សូមបង់ថ្លៃទិញធានារ៉ាប់រងរបស់អ្នក នៅមុនថ្ងៃកំណត់ទៅឱ្យក្រុមហ៊ុនធានារ៉ាប់រងសុខភាពដែលអ្នកជ្រើសរើស — **មិនមែនបង់ទៅឱ្យ Covered California ទេ ។**

សម្រាប់ព័ត៌មានបន្ថែម ឬដើម្បីស្វែងរកជំនួយក្នុងតំបន់ ដោយឥតគិតថ្លៃ និងរក្សាសម្ងាត់ សូមទាក់ទង :

CoveredCA.com | (800) 300-1506

### តើមានសំណួរបន្ថែមឬ?

សូមមើលវីដេអូ “Welcome to Answers” នៅ CoveredCA.com/FAQs



(សម្គាល់: “Welcome to Answers” គឺជាសេរីវីដេអូជូនព័ត៌មានដែលមានជាភាសាអង់គ្លេសតែប៉ុណ្ណោះ)

### ប្រធានបទរាប់បញ្ចូល:

- តើ Covered California គឺជាអ្វី?
- តើខ្ញុំចុះឈ្មោះតាមរបៀបណា?
- តើ Covered California អាចជួយអ្នកមានអាយុក្រោម 30 ឆ្នាំបានដោយរបៀបណា?
- តើ Covered California ធ្វើឱ្យធានារ៉ាប់រងមានតម្លៃសមរម្យតាមរបៀបណា?
- តើ Affordable Care Act ផ្លាស់ប្តូរធានារ៉ាប់រងសុខភាពតាមរបៀបណា?

មានអ្នកបកប្រែជូនអ្នកហៅទូរស័ព្ទមកដែលស្វែងរកជំនួយជាភាសាផ្សេងទៀត